ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា

នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦

សូមគោរព :

- គណៈអធិបតី!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

នាពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ របស់យើង បានឈានដល់ទីបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ថា សន្និបាតរបស់យើងបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាល ក្នុងស្មារតីសាមគ្គីភាពនិងភាតរភាពបំផុត ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំរបស់យើង ដែលបានធ្វើបទបង្ហាញនិងបទអន្តរាគមន៍អំពីលទ្ធផលចម្បងៗដែលសម្រេចបាន និងទិសដៅការងារសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា និងចំពោះការចូលរួមយ៉ាងសកម្មនិងដោយយកចិត្តទុកដាក់ខ្ពស់របស់សមាជិក-សមាជិកានៃអង្គសន្និបាតទាំងមូល ។ ខ្ញុំសូមឯកភាពលើការបូកសរុបលទ្ធផល ទស្សនវិស័យ និងមតិ ដែលបានលើកឡើងរបស់ថ្នាក់ដឹកនាំយើង ដែលពិតជាមានសារៈសំខាន់ណាស់ក្នុងការសម្រេចឱ្យបានសមិទ្ធិផលថ្មីៗបន្ថែមទៀត ជូនធនាគារជាតិនៃកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ការបន្តងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសនៅក្នុងប្រទេសជាដៃគូពាណិជ្ជកម្មនិងវិនិយោគជាមួយកម្ពុជា នឹងអាចផ្តល់ភាពអំណោយផលដល់កំណើននៃ

*អគ្គនាយកដ្ឋានបច្ចេកទេស/នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ*



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការនាំចេញ ការវិនិយោគផ្ទាល់បរទេស និងវិស័យទេសចរណ៍នៅកម្ពុជា ។ កត្តាទាំងនេះ គួបផ្សំនឹងកំណើនតម្រូវការនិងការវិនិយោគក្នុងស្រុក បានធ្វើឱ្យកំណើនសេដ្ឋកិច្ចរំពឹងថា នឹងបន្តកើនឡើងក្នុងរង្វង់ ៧% ក្នុងរយៈកាលមធ្យម ជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុរឹងមាំ ។

ទោះជាយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏អាចទទួលរងឥទ្ធិពលនៃការប្រែប្រួលសេដ្ឋកិច្ច ពិភពលោកផងដែរ ដោយសារកម្ពុជាមានកម្រិតបើកចំហខ្ពស់ និងពឹងផ្អែកលើវិស័យ ខាងក្រៅដើម្បីជំរុញកំណើន ទន្ទឹមនឹងកម្លាំងជំរុញនៃតម្រូវការក្នុងស្រុក ។ ក្នុងស្ថានភាពនេះ ភាពមិនច្បាស់លាស់នៃកំណើនសេដ្ឋកិច្ចពិភពលោក និងស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ អាចធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាប្រឈមនឹងហានិភ័យចម្បងៗមួយចំនួន រួមមាន ៖

i/- ភាពរឹតត្បិតនៃស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិនិងតំបន់ កំណើនយឺតនៃ សេដ្ឋកិច្ចសហភាពអឺរ៉ុបនិងអង់គ្លេស ជាពិសេស ក្រោយពីការប្រកាសចាកចេញរបស់ អង់គ្លេសពីសហភាពអឺរ៉ុប (Brexit)

ii/- ឥទ្ធិពលនៃការថមថយល្បឿនកំណើនសេដ្ឋកិច្ចចិន លើកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារកំណើនទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ រវាងប្រទេសទាំងពីរ និង

iii/- ការកើនឡើងនៃការប្រកួតប្រជែងលើទីផ្សារនាំចេញ បន្ទាប់ពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ។

ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងគោលនយោបាយនិងវិធាន ការដែលមានស្រាប់និងដាក់ចេញនូវវិធានថ្មីនានា ដើម្បីបន្តរួមចំណែកពង្រឹងភាពធន់នៃ មូលដ្ឋានម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យធនាគារ និងស្ថិរភាពហិរញ្ញវត្ថុ សំដៅគាំទ្រការរីក ចម្រើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌ ស្របតាមគោលនយោបាយ ចតុកោណ ដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្នុងស្មារតីនេះ ខ្ញុំសូមផ្ដាំផ្ញើមតិមួយចំនួន ដើម្បីបន្តសម្រេចបាននូវសមិទ្ធិផលថ្មីៗ បន្ថែមទៀត នៅឆមាសទី២ ឆ្នាំ២០១៦នេះ និងនៅក្នុងរយៈកាលមធ្យមខាងមុខ ដូច ខាងក្រោម ៖

- បន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ប្រកបដោយភាពទន់ភ្លន់ ស្របតាមការរីកចម្រើនសេដ្ឋកិច្ច
- អភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ និងទីផ្សារប្តូរប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយ
- អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ ដែលរួមចំណែកបង្កើនប្រសិទ្ធភាពការអនុវត្តគោលនយោបាយរូបិយវត្ថុ
- អភិវឌ្ឍប្រព័ន្ធទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព ឆាប់រហ័ស និងតម្លៃសមរម្យ
- បញ្ចប់ការចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជាចំពោះគ្រឹះស្ថាន និងអង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់សេវាមីក្រូហិរញ្ញវត្ថុក្រៅប្រព័ន្ធឱ្យចប់សព្វគ្រប់មុនដំណាច់ឆ្នាំ២០១៦
- អនុវត្តតាមអនុសាសន៍ទាំង ៥ ចំណុចដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកឡើងក្នុងសន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ កន្លងមក ក្នុងគោលបំណងអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីគាំទ្របរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងបង្កើនជីវភាពរស់នៅរបស់ប្រជាជន
- បន្តសហការជាមួយភាគីពាក់ព័ន្ធ ក្នុងការរៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ ហើយបន្តពង្រឹងការអនុវត្តកិច្ចការពារអតិថិជន និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ
- បន្តផ្សព្វផ្សាយសេចក្តីថ្លែងការរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុ
- ពង្រឹងប្រសិទ្ធភាពទប់ស្កាត់និងប្រឆាំងរាល់សកម្មភាពនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រព័ន្ធធនាគារ
- បន្តអភិវឌ្ឍធនធានមនុស្សលើឯកទេសកម្មចំណេះដឹងជំនាញ ដោយផ្តោតលើការងារអាទិភាពជាក់ស្តែង
- ពង្រឹងនិងពង្រីកសហប្រតិបត្តិការអន្តរជាតិជាមួយស្ថាប័នហិរញ្ញវត្ថុ ធនាគារកណ្តាល និងភាគីពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ និងទទួលបានជំនួយបច្ចេកទេសអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស និង

- ពង្រឹងការងារទំនាក់ទំនងរបស់ធនាគារជាតិនៃកម្ពុជា ជាមួយភាគីពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងរបស់សាធារណជនក៏ដូចជាស្ថាប័នជំនាញនានា ពីតួនាទី គោលនយោបាយ និងវិធានការនានារបស់ធនាគារជាតិនៃកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សមាជិក-សមាជិកាអង្គសន្និបាតរបស់យើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃសមិទ្ធផលការងារនិងទិសដៅ ដែលលើកឡើងក្នុងអង្គសន្និបាតនាថ្ងៃនេះ និងបន្តយកទៅផ្សព្វផ្សាយនៅក្នុងនាយកដ្ឋាននិងអង្គភាពរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចបាននូវសមិទ្ធផលបន្ថែមទៀតក្នុងឆមាសទី២ នៅឆ្នាំ២០១៦ និងនាពេលខាងមុខ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យកាន់តែទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិនិងអន្តរជាតិ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងជាស្ថាពរ ។**

**សូមអរគុណ!**